# មជ្ឈមណ្ឌលឯកសារកម្ពុជា

## *សេក ដន ភេទប្រុស* **K09131 (*នៅរស់*)**

*មុខងារៈ ពេទ្យឃុំ*

*សម្ភាសជាមួយ សេង ដន អាយុ៤៧ ឆ្នាំ ជាម្ចាស់ប្រវត្តិរូប*

*រស់នៅក្នុងភូមិត្រពាំងក្រពៅ ឃុំខ្ពង់ពពក ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង*

*ធ្វើនៅថ្ងៃទី១១ ខែឧសភា ឆ្នាំ២០០៥*

*សម្ភាសដោយៈ ដាន់ សុដា*

*សរុបៈ ២៥ទំព័រ*

### *យោបល់អ្នកសម្ភាសៈ*

*តាមការសម្ភាសន៍ខ្ញុំជាមួយហ្នឹងលោកពូ សេក ដន យើងបានដឹងថាពូត្រូវបានគេបង្ខំឲ្យចូលបក្សបដិវត្តន៍នៅក្នុងជំនាន់ ប៉ុល ពត មុនដំបូងពូទៅធ្វើនៅក្នុងកងកុមារត្រូវបានគេឲ្យរៀនបានពីរឆ្នាំ ហើយក្រោយមកគេជ្រើសរើសពូឲ្យទៅធ្វើការនៅទីក្រុងភ្នំពេញ គាត់ថាប្រហែលជាឆ្នាំ៧៦អី តែគាត់មិនបានបញ្ជាក់ឲ្យបានច្បាស់លាស់ទេ ហើយមានការវ៉ៃជាមួយហ្នឹងវៀតណាម ពីព្រោះខ្មែរក្រហមគេបានប្រមូលប្រជាជនពីស្រុកភូមិឃុំនៅក្នុងខេត្តកំពង់ឆ្នាំង ហើយគាត់និយាយថាយុទ្ធជនធំៗត្រូវបានគេឲ្យកាន់កាំភ្លើងទៅវ៉ៃជាមួយហ្នឹងវៀតណាម ចំណែកឯប្រជាជនតូចៗត្រូវបានគេរើសឲ្យទៅធ្វើការនៅទីក្រុងភ្នំពេញ ចំណែកពូដូចថាគាត់នៅមានអាយុប្រហែលតែ១២-១៣ឆ្នាំ គាត់ត្រូវបានគេឲ្យទៅធ្វើពេទ្យព-១ នៅទល់មុខពេទ្យ៦មករា យើងឃើញថានៅក្នុងជំនាន់ ប៉ុល ពត នៅពេលដែលវ៉ៃជាមួយហ្នឹងវៀតណាម ប៉ុល ពត បានរើសយុវជនជាច្រើនឲ្យទៅបំរើការនៅក្នុងមន្ទីរពេទ្យ ហ្នឹងនៅទីកន្លែងផ្សេងៗរហូតទៅដល់វ៉ៃជាមួយហ្នឹងពួកវៀតណាមក៏មាន ព្រោះ ប៉ុល ពត ត្រូវការកំលាំងជាច្រើនគឺដោយសារតែខ្លួនបានសម្លាប់យុទ្ធជនចាស់អស់ចំនួនច្រើន គឺដូចជាយើងបានទៅសម្ភាសន៍ជាច្រើននៅក្នុងខេត្តកំពង់ឆ្នាំង ដែលទៅធ្វើពេទ្យ ហើយសុទ្ធតែជាយុទ្ធជនក្មេងដែលចេញទៅនៅក្នុងឆ្នាំ៧៦-៧៧ ខ្ញុំអស់ត្រឹមតែប៉ុណ្ណឹង ។*

សុជាៈ ពូខ្ញុំមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា ជាអ្នកសិក្សារឿងប្រវត្តិខ្មែរក្រហមគឺប្រវត្តិនៅក្នុងជំនាន់៣ឆ្នាំ ហើយខ្ញុំមករកពូនេះតាមរយៈឯកសារមួយសន្លឹក ដែលគេដាក់ថាពូនៅធ្វើការនៅភ្នំពេញគឺនៅក្នុងជំនាន់៣ឆ្នាំនិងណា ឥឡូវខ្ញុំដឹងការងារនិងជីវិតរបស់ពូកាលនៅក្នុងជំនាន់ហ្នឹង ពូមានឈ្មោះអីដែរពូ?

ជនៈ ឈ្មោះជន ។

សុជាៈ ពូមានអាយុប៉ុន្មានដែរពូ?

ជនៈ កាលនោះខ្ញុំនៅកុមារនៅឡើយទេ ។

សុជាៈ ចុះឥឡូវអាយុប៉ុន្មានហើយ?

ជនៈ ឥឡូវចាស់ហើយអាយុ ៤៧ឆ្នាំហើយ ។

សុជាៈ ពូឈ្មោះអីគេជន?

ជនៈ រាល់ថ្ងៃនេះដាក់ថា សេង ជន ។

សុជាៈ ចុះពីមុនដាក់ឈ្មោះអីដែរ?

ជនៈ ពីមុនខ្ញុំប្រើត្រកូលដួង ។

សុជាៈ ដួង ជន អីចឹងទៅ?

ជនៈ បាទ! ឪពុកខ្ញុំឈ្មោះដួង ។

សុជាៈ ឪពុកពូឈ្មោះដួង អីគេដួង?

ជនៈ មិនដឹងជាអីទេ ខ្ញុំអត់សូវស្គាល់ដែរ ។

សុជាៈ ចុះឪនោះ?

ជនៈ គាត់និងតាខ្ញុំ ។

សុជាៈ លោកតាឈ្មោះ សេក ឌី ដែរ?

ជនៈ បាទ! ។

សុជាៈ ចុះម្តាយពូ?

ជនៈ សុខ ធិន ។

សុជាៈ ម្តាយនៅរស់ដែរ?

ជនៈ ម្តាយនៅរស់ ។

សុជាៈ អញ្ចឹងនៅរស់ទាំងពីរ?

ជនៈ បាទ! ។

សុជាៈ ពូមានបងប្អូនប៉ុន្មាននាក់ដែរ?

ជនៈ ៦ នាក់ ។

សុជាៈ បងប្អូនពូទាំងអស់៦ នាក់ ចុះឥឡូវនៅសល់ប៉ុន្មានដែរ?

ជនៈ នៅសល់៤នាក់ ។

សុជាៈ អញ្ចឹងស្លាប់អស់ពីរ?

ជនៈ បាទ! ។

សុជាៈ ស្លាប់ដោយសារអីដែរ?

ជនៈ ខ្ញុំអត់ដឹងផង ព្រោះខ្ញុំនៅបែកគ្នាដល់ពេលដែលខ្ញុំមក ស្រាប់តែបាត់អស់ទៅអត់ដែលឃើញផង

សុជាៈ អញ្ចឹងបាត់ខ្លួន បាត់តាំងពីជំនាន់ប៉ុលពត?

ជនៈ បាទ! ឪខ្ញុំគាត់ថាស្លាប់ ។

សុជាៈ មូលហេតុអី?

ជនៈ ខ្ញុំអត់ដឹងដែរ ព្រោះខ្ញុំអត់ដែលជួបគាត់ ។

សុជាៈ មុននិងគាត់បាត់ខ្លួនឬក៏ស្លាប់ហ្នឹង តើគាត់ឈឺអីដែរ?

ជនៈ កាលហ្នឹងគាត់នៅកុមារ ។

សុជាៈ ហើយគាត់ចេញទៅពីផ្ទះទៅឬក៏ម៉េច?

ជនៈ គេយកទៅដាក់នៅការដ្ឋានកោះបូ ។

សុជាៈ កោះអីគេ?

ជនៈ កោះបូនៅកំពង់ឆ្នាំង ។

សុជាៈ យកចេញពីផ្ទះហ្នឹងទៅ?

ជនៈ បាទ! ។

សុជាៈ ចុះម្នាក់ទៀត?

ជនៈ ម្នាក់ទៀតលឺថាទៅវ៉ៃនៅក្រចេះកាលហ្នឹងទៅវ៉ៃជាមួយវៀតណាម រួចដល់ពេលមកវិញថារបួស ក្រោយមកលឺថាស្លាប់នៅឯណាណោះ ។

សុជាៈ ពូគ្រួសារពូឈ្មោះអីដែរ?

ជនៈ ឈ្មោះម៉េន ។

សុជាៈ ឈ្មោះអី?

ជនៈ ម៉េន ។

សុជាៈ គាត់មានអាយុប៉ុន្មានដែរ?

ជនៈ គាត់មានអាយុ៤៦ ។

សុជាៈ ពូមានកូនចៅប៉ុន្មាននាក់ដែរ?

ជនៈ កូនចៅខ្ញុំមាន៦នាក់ដែរ ។

សុជាៈ ពូរាល់ថ្ងៃនេះប្រកបរបរធ្វើអីដែរ?

ជនៈ ធ្វើស្រែចំការ ។

សុជាៈ គាត់កើតជានៅឆ្នាំណាដែរ?

ជនៈ មិនដឹងជាកើតនៅឆ្នាំណាទេ ។

សុជាៈ ដូចឆ្នាំខ្មែរយើង ឆ្នាំសត្វអីគេ?

ជនៈ ឆ្នាំឆ្លូវ ។

សុជាៈ គាត់កើតជានៅឯណាដែរ?

ជនៈ គាត់កើតនៅខ្ទង់ពពក នេះទើបតែមកនៅថ្មីទេ ។

សុជាៈ ភូមិខ្ទង់ពពក ឃុំ?

ជនៈ ឃុំក៏ខ្ទង់ពពកដែរ ។

សុជាៈ ស្រុកអីគេអាហ្នឹង?

ជនៈ ស្រុកទឹកផុស ។

សុជាៈ ខាងខេត្តកំពង់ឆ្នាំង?

ជនៈ បាទ! ។

សុជាៈ កាលនៅពីតូចពូមានដែលទៅរៀនទៅបួសអីដែលទេ?

ជនៈ អត់បានបួសផង តែបាននៅវត្តអីបន្តិចបន្តួច ។

សុជាៈ នៅវត្តធ្វើអីគេដែលទៅ?

ជនៈ	នៅវត្តអត់មានធ្វើអីផង ។

សុជាៈ	នៅជាមួយលោកអីហ្នឹង?

ជនៈ	បាទ! ពីដើមនៅជាកូនសិស្សលោក ។

សុជាៈ	ពូចុះពេលណាដែលពីចូលទៅកងទ័ពជួរគេ?

ជនៈ	កាលនោះគេរើសទៅកុមារ ។

សុជាៈ	ពូទៅកុមារទេ?

ជនៈ	បាទ! ។

សុជាៈ	ហើយនៅជំនាន់ពូនៅនិងភូមិពូនេះ តើពូមានដឹងដែលទេថាខ្មែរក្រហមនិងចូលមកនៅនិងភូមិពូនេះនៅឆ្នាំណាដែរ?

ជនៈ	មិនដឹងជាឆ្នាំណាផង ពីព្រោះកាលនោះខ្ញុំនៅតូចពេកដែរ កាលនៅវត់និងខ្ញុំនៅកុមារដែរ ទើបរួចខ្លួនកាលនៅឆ្នាំ៧៩និងនៅកុមារដែរ កុមារពេទ្យចឹង ។

សុជាៈ	ចុះពេលដែលប៉ុលពតចូលមកភូមហ្នឹង តើគេអោយពូចូលកងកុមារដែរឬក៏នៅធ្វើអីដែរ?

ជនៈ	ដែលនៅពីជំនាន់អាពតនោះខ្ញុំនៅជាកុមារនៅឡើយទេ ។

សុជាៈ	នៅក្នុងផ្ទះឬក៏នៅក្នុងកងអី?

ជនៈ	នៅជាមួយនិងម្តាយឪពុកនៅឡើង ប៉ុនគ្រាន់តែទៅរៀនហើយមកហូបបាយអីនៅផ្ទះវិញ ទាល់តែពេលនេះបានគេយកទៅ ។

សុជាៈ	នៅពេលណាដែរ?

ជនៈ	រៀនសាលាយើងនៅតាមភូមិដែលគេហៅសាលាអប់រំនោះណា ។

សុជាៈ	រៀននៅសាលាអប់រំ?

ជនៈ	បាទ! ។

សុជាៈ	គ្រូឈ្មោះអីដែរ?

ជនៈ	នឹម ។

សុជាៈ	គ្រូនឹម នឹមនិងគាត់ស្រីប្រុស?

ជនៈ	ស្រី ។

សុជាៈ	គាត់ជាអ្នកដែលនៅនិងដែរឬក៏មកពីណា?

ជនៈ　　គាត់ជាអ្នកនៅនិងភូមិចាស់និងដែរ ។

សុជាៈ　　កាលរៀននៅជំនាន់ប៉ុលពតហ្នឹង គេអោយរៀនម៉េចដែរមួយថ្ងៃគេអោយរៀនប៉ុន្មានម៉ោង?

ជនៈ　　គេរៀនកិច្ចការរាំអីបន្តិចបន្តួចនិងណា ។

សុជាៈ　　មានសិល្បៈមានរាំអីចឹងដែរ?

ជនៈ　　បាទ! ។

សុជាៈ　　តែរៀនមួយថ្ងៃពេញឬក៏ម៉េច?

ជនៈ　　អត់ទេរៀនអត់ដល់មួយថ្ងៃពេញទេ រៀនតែមួយព្រឹកៗ ។

សុជាៈ　　ចុះថ្ងៃធ្វើអី?

ជនៈ　　អត់មានធ្វើអីផង ។

សុជាៈ　　មកផ្ទះវិញមក?

ជនៈ　　បាទ! ។

សុជាៈ　　ហើយរៀនបានប៉ុន្មានឆ្នាំ?

ជនៈ　　រៀននៅជំនាន់អាពតនិងបានពីរឆ្នាំ ។

សុជាៈ　　នៅជំនាន់ប៉ុលពតហ្នឹង?

ជនៈ　　បាទ! ។

សុជាៈ　　ចុះក្រោយពីរៀនមក?

ជនៈ　　ក្រោយពីរៀនមកគេយកទៅហ្វឹកបាត់ទៅ ។

សុជាៈ　　គេយកទៅណា?

ជនៈ　　គេយកទៅជាមួយគេនិងណា អាមួយនោះវាបានទៅមុនហើយវាមកយក ។

សុជាៈ　　ពីណាគេបានទៅមុន?

ជនៈ　　អាអ្នកដែលនៅសាលាជាមួយគ្នានិងណា វាបានជាប់ឈ្មោះទៅមុនហើយវាមកយកខ្ញុំ ។

សុជាៈ　　មកយកពូទៅដែរ?

ជនៈ　　បាទ! វាថាបានពីរអ្នកដែរអ្នកនៅស្រុកយើង ប៉ុនវាស្លាប់បាត់ហើយ ។

សុជាៈ　　ឈ្មោះអីគេ?

ជនៈ　　ឈ្មោះអីទេ វានៅឆ្ងាយដែរណាវានៅឯកើតណោះ ប៉ុនវាស្លាប់បាត់ហើយ ។

សុជាៈ	ពូមានចាំឈ្មោះគាត់អត់?

ជនៈ	ចាំ ។

សុជាៈ	ឈ្មោះអីគេ?

ជនៈ	ឃីម ។

សុជាៈ	គាត់មានអាយុច្រើនជាងពូ?

ជនៈ	គាត់មានអាយុច្រើនជាងខ្ញុំ កាលនោះខ្ញុំនៅតូចគេគ្រាន់ធំហើយណា ។

សុជាៈ	គាត់ទៅបានប៉ុន្មានខែបានមកយកពូទៅ?

ជនៈ	អត់ទេវានៅនិងដែរ តែវាជាសិស្សដែលធំជាងគេ ។

សុជាៈ	ហើយមានអ្នកផ្សេងទៀតអីទៅជាមួយពូនិងគាត់ដែលទេ?

ជនៈ	អត់មានទេ ទៅតែពីរអ្នកទេ ។

សុជាៈ	ហើយឃីមនិងគាត់មិនមែនអ្នកភូមិយើងខ្ទុំពពកនៅនិងក្របៅនិងទេ?

ជនៈ	មិនមែនទេ ។

សុជាៈ	គាត់នៅភូមិអីគេ?

ជនៈ	គាត់នៅត្រពាំងជ្រៃ ។

សុជាៈ	គាត់ស្លាប់ដោយសារអី?

ជនៈ	កាលដែលចុះមកខ្មែរក្រហមដណ្តើមបាយអីគ្នាស៊ី កាលដែលប្រជាជនចុះទៅក្រោមអស់នោះ វានៅក្រោយគេបាញ់ដណ្តើមបាញ់គ្នាស៊ីក៏ស្លាប់អស់ទៅ ។

សុជាៈ	ពេលពូទៅចឹងដូចថាឪពុកម្តាយពូអីគាត់មានដឹងទេ?

ជនៈ	គាត់ដឹង ។

សុជាៈ	ហើយគាត់មាននិយាយថាម៉េចដែរ?

ជនៈ	អត់មាននិយាយថាម៉េចទេ នៅសម័យនោះអត់មានអ្នកណាហ៊ាននិយាយតវ៉ាអីទេ ។

សុជាៈ	ចុះពេលពូឃីមមកយកពូទៅ តើពូឃីមនិងគាត់អាចធានាយកពូទៅឬក៏មានអ្នកផ្សេង?

ជនៈ	អត់ទេគេរើសក្នុងនិងណា ដល់ពេលនេះវាធំជាងគេវាថាមកទៅជាមួយអញគ្រាន់បានគ្នាពីរនាក់ដែលនៅស្រុកពីរអ្នកនៅស្រុកឯង ។

សុជាៈ	ពីណាគេជាអ្នកមករើសមានដឹងទេ?

ជនៈ	កាលជំនាន់នោះមិនដឹងជាពីណាមករើស  ប៉ុនគ្រូនៅនឹងគេជាអ្នករើសយកទៅអោយ  ប៉ុនខ្ញុំអត់សូវស្គាល់គេដែរ ។

សុជាៈ	គ្រូនីមហ្នឹង?

ជនៈ	បាទ! ។

សុជាៈ	គ្រូនីមនិងជាអ្នករើសក៏មិនមែនទេ?

ជនៈ	គ្រូគេជាអ្នករើសទៅ  ប្រហែលជាគេស្នើដឹងគេទៅហៅនៅសាលាឯព្រៃដើងនោះមកជួបគេក៏ទៅបណ្ដោយ ។

សុជាៈ	ព្រៃអីគេ?

ជនៈ	បាទ!  មកពីព្រៃដើងមក  គេហៅទៅជាមួយគេទៅ  គេអោយមកជួបជុំគេនៅនិង២-៣នាក់ទៅ ។

សុជាៈ	ហើយនៅក្នុងភូមិនិងទៅប៉ុន្មាននាក់?

ជនៈ	នៅក្នុងភូមិខ្ញុំកាលដែលទៅនិងគឺពីរអ្នក ។

សុជាៈ	ពូហើយនិងឈ្មោះឃីមហ្នឹង?

ជនៈ	បាទ! ។

សុជាៈ	ពេលគាត់ហៅពូទៅចឹង  ទៅពីរអ្នកអីចឹងតើគេយកទៅដាក់នៅត្រឹមណាអីឬក៏មានទៅណាទៀត?

ជនៈ	គេយកទៅដាក់នៅសាលាលេខ៩ ។

សុជាៈ	ពីនិងទៅជិះអីទៅ?

ជនៈ	អោយដើរ ។

សុជាៈ	ដើរទៅរហូត  ដើរប៉ុន្មានថ្ងៃ?

ជនៈ	ដើរមួយថ្ងៃ  តាំងពីព្រឹកចឹងរហូតដល់ថ្ងៃល្ងាចបានដល់ ។

សុជាៈ	ដើរតែពីរអ្នកហ្នឹង?

ជនៈ	ដើរមានគ្នាដែរ  មកពីស្រុកគេស្រុកឯងដែរតែអត់ស្គាល់គេ ។

សុជាៈ	អត់ទេដើរពីនេះទៅប៉ុន្មាននាក់?

ជនៈ	ដើរគ្នាច្រើន  ១០-២០នាក់ ។

សុជាៈ	គេមកពីឃុំផ្សេងៗ?

ជនៈ	បាទ!  អត់ស្គាល់គេ ។

សុជាៈ ហើយកាលនិងនៅឆ្នាំណាមានចាំទេ?

ជនៈ មិនដឹងជានៅចិតប៉ុន្មានដែរ ។

សុជាៈ តែគេជំលៀសប្រជាជនមកអស់ហើយ?

ជនៈ មកអស់ហើយ ។

សុជាៈ បាយគេអីនៅសហករណ៍អីហ្នឹង?

ជនៈ បាទ! ។

សុជាៈ ដើរទៅចឹងមានអ្នកនាំមានអ្នកយាមអីដែលទេ?

ជនៈ មានឈ្លបគេ ។

សុជាៈ ឈ្លបប៉ុន្មាននាក់?

ជនៈ ឈ្លបគេ៣នាក់ ជូនទៅដាក់នៅកន្លែងគេនោះ ។

សុជាៈ មានកាំភ្លើងទេឈ្លបហ្នឹង?

ជនៈ បាទ! គេមានកាំភ្លើងរបស់គេ ។

សុជាៈ គេធំៗជាងយើង?

ជនៈ ឈ្លបគេធំៗ ចាស់ៗអស់ហើយ ។

សុជាៈ ចុះដើរទៅតាមផ្លូវចឹងដូចមានពួកសហករណ៍គេអីចឹង?

ជនៈ គេគ្រាន់តែទាក់ទងគ្នារកទឹកដឹកហ្នឹង ។

សុជាៈ ចុះបាយទឹកអី?

ជនៈ បាយដល់ពេលនេះគេហៅហូបបាយហូបអីទៅ គេបញ្ជូនទៅទៀតទៅ ។

សុជាៈ សហករណ៍គេអត់មានសួរនាំអី?

ជនៈ អត់ទេ បើគេសួរនាំគេសួរនាំតែអ្នកធំៗនោះឯង ។

សុជាៈ គេសួរអ្នកឈ្លបនិងទៅ?

ជនៈ បាទ! មកចឹងគេអត់មានសួរថាទៅណាទៅណី អត់ទេ ។

សុជាៈ មានស្រីទេ?

ជនៈ ទេកាលនោះមាន ។

សុជាៈ ចំនួនប្រហែលជាប៉ុន្មាននាក់?

ជនៈ ប្រហែលជាជាង១០នាក់ណោះកាលហ្នឹង ។

សុជាៈ ឧបមារថាដើរពីនេះទៅមិនកាត់ឃុំកាត់ស្រុកអី ដូចស្រុករលៀផ្អៀរ, ស្រុកកំពង់ត្រឡាចអីទៀតណែ ចុះទំរាំតែទៅដល់និងគេមានអ្នកទៅតាមផ្លូវអីទៅជាមួយទៀតដែលទេ?

ជនៈ មាន គេដើរតាមខ្សែរយះគេ ហើយពួកខ្ញុំគឺចេះតែទៅៗ ទៅដល់នេះគេផ្ញើរទៅទៀតទៅ ទៅដល់នោះគេផ្ញើរទៅទៀតទៅ ចេះតែទៅតាមគេទៅមួយកន្លែងៗចឹង ។

សុជាៈ ចេញពីទឹកផុសនេះទៅ?

ជនៈ ទៅដល់ត្រពាំងល្ហា ។

សុជាៈ ទៅដល់ត្រពាំងល្ហាគេបញ្ជូនតទៅទៀត?

ជនៈ បាទ! ។

សុជាៈ ទៅដល់នោះគេមានឈ្លបគេបញ្ជូនតទៅទៀតទៅ?

ជនៈ ឈ្លបគេបញ្ជូនទៅដាក់នៅកន្លែងគេ ដូចជាមន្ទីរគេដូចជាប៉ុស្តិ៍ប៉ូលីសចឹងណា មកដល់ត្រឹមនិងគេដាក់នៅនិងទៅ ហើយនេះយកទៅដាក់នៅនោះទៅទៀតៗ គេចាក់តែដាក់តទៅទៀតទៅណា ពួកខ្ញុំចេះតែមកណោះទៀតទៅណា ។

សុជាៈ ហើយឈ្លបគេមកវិញមក?

ជនៈ បាទ! គេបញ្ជូនមកដល់កន្លែងគេហើយ គេត្រឡប់ទៅកន្លែងវិញទៅ ហើយនេះគេបញ្ជូនទៅទៀតទៅណា ។

សុជាៈ ដើរកាត់តាមណា?

ជនៈ កាត់សែត ។

សុជាៈ អានិងមិនមែនទៅតាមយើងចុះទៅរមាសអីទេ?

ជនៈ អត់ទេ កាត់តាមព្រៃ តាមផ្លូវលំតែខ្ញុំវាអត់សូវស្គាល់ដែរណា ព្រោះខ្ញុំនៅកាលនោះនៅតូចដែរបើធំចេះបែបស្គាល់ ។

សុជាៈ ពូមានចាំទេកាលហ្នឹងពូមានអាយុប៉ុន្មាន?

ជនៈ កាលហ្នង់អាយុ១១ដឹង ខ្ញុំនៅតូចៗ ។

សុជាៈ ទំរាំទៅដល់សាលាលេខ៥កំពង់ត្រឡាចហ្នឹង តើមានគ្នាប៉ុន្មាននាក់ទៅ?

ជនៈ ទៅដល់មានច្រើន ។

សុជាៈ	បើមើលទៅចូលពាន់ដែលទេ?

ជនៈ	ទេច្រើនដែរតែមិនដល់ចូលពាន់ទេ ។

សុជាៈ	មកពីខាងណាខ្លះទៅ?

ជនៈ	មកពីជុំវិញកំពង់ឆ្នាំងហ្នឹង មកពីគ្រប់តែកន្លែងហ្នឹងឯង ។

សុជាៈ	នៅហ្នឹងមនុស្សច្រើនដែរ ហើយគេអោយស្នាក់នៅហ្នឹងប៉ុន្មានថ្ងៃទៅ?

ជនៈ	......... ។

សុជាៈ	ពេលដែលមកចឹងតើគេបញ្ជូនអោយទៅកន្លែងណាទៀតទៅ?

ជនៈ	វាបែកគ្នាខ្ទេចខ្ទីអស់ ដល់ពេលដែលដល់កន្លែងគេគឺបំបែកគ្នាអស់ ទៅតាមអង្គភាពអីទៅគឺគេបែកគ្នានៅនោះ ខ្លះទៅធ្វើជាទាហានវ៉ៃយួនវ៉ៃអីចឹងទៅ ។

សុជាៈ	អញ្ចឹងកាលនោះចាប់ផ្តើមមានវ៉ៃយួនហើយ?

ជនៈ	មានហើយ មានគេរើសចូលទៅធ្វើទ័ពអីវ៉ៃយួនហើយ ទៅតាមអង្គភាពនេះតាមអង្គភាពនោះទៅ

សុជាៈ	ហើយកាលហ្នឹងដូចថាអាយុ១២-១៣អីហ្នឹងមើលទៅច្រើនគ្នាដែលទេ ច្រើនជាងពួក១៨-១៩អី?

ជនៈ	ច្រើន តែអាធំៗគេច្រើនជាង ។

សុជាៈ	ហើយក្មេងៗក៏ច្រើនដែរ?

ជនៈ	បាទ! ច្រើនដែរ ។

សុជាៈ	ហើយកាលហ្នឹង គេមាននិយាយថាទៅធ្វើសង្គ្រាមវ៉ៃវៀតណាមអីដែលទេ តើគេមាននិយាយដែលទេ?

ជនៈ	គេនិយាយថាយួនឈ្លានពាន ។

សុជាៈ	ហើយដល់ពេលនៅហ្នឹង តើក្រោយមកទៀតទៅនៅឯណាដែរ?

ជនៈ	នៅហ្នឹងរហូតទាល់តែដល់ពេលដែលរត់ហ្នឹងហ្មង ។

សុជាៈ	អត់ទេអាពេលដែលនៅកំពង់ត្រឡាចនេះ?

ជនៈ	ចេញពីកំពង់ត្រឡាចទៅភ្នំពេញហ្មង ។

សុជាៈ	គេដឹកអីទៅ?

ជនៈ	ឡានទៅ ។

សុជាៈ	ប៉ុន្មានឡាន?

ជនៈ	ពីរឡានទៅ ។

សុជាៈ	មានប្រុសមានស្រីអីទៅ?

ជនៈ	បាទ! ។

សុជាៈ	ពេលដែលទៅដល់ភ្នំពេញ តើគេឲ្យទៅនៅកន្លែងណាទៅ?

ជនៈ	គេឲ្យទៅធ្វើពេទ្យ ។

សុជាៈ	ទៅដល់មុនដំបូងគេឲ្យឈប់នៅកន្លែងណាទៅ?

ជនៈ	មិនដឹងជាឈប់នៅត្រង់ណាៗអីទេ ។

សុជាៈ	ចុះបើពីរដូវវិញ តើនៅរដូវភ្លៀងឬក៏នៅរដូវក្តៅ?

ជនៈ	ទៅកាលហ្នឹងមិនដឹងជាទៅនៅខែណាផង មិនដឹងជាទៅនៅខែហ្នឹងមិនដឹង ជាទៅខែវស្សាមិនដឹង តែកាលហ្នឹងដើរទៅអត់មានទឹកផុកអីដែរ ។

សុជាៈ	ចុះដល់ពេលដែលទៅចិន ហើយអ្នកដែលគេរើសទៅជាមួយពូចិនប៉ុន្មាននាក់ទៅ?

ជនៈ	៦នាក់ តែគេទៅផ្សេងៗគ្នា ។

សុជាៈ	ចុះឃីមនោះ?

ជនៈ	ឃីមនោះបែកនៅសលាលេខ៥ វាធំគេយកទៅណាណោះ គេយកទៅព្រំដែនអីណោះ នៅស្វាយរៀងណាណោះ ពួកខ្ញុំគេយកតែអាតូចៗអាធំគេបញ្ជូនទៅផ្សេង ។

សុជាៈ	នៅភូមិនេះគេមកឃោសនាថាយកទៅធ្វើពេទ្យ?

ជនៈ	គេមកថាឲ្យទៅធ្វើជាទាហាន ។

សុជាៈ	ចុះម៉េចបានពូដឹងថា ពូឃីមហ្នឹងគេឲ្យទៅវៃជាមួយវៀតណាមវិញ?

ជនៈ	កាលនោះគេថាពួកអាធំៗគេរើសទៅផ្សេង អាតូចគេឲ្យនៅពីក្រោយពួកអាធំៗគេឲ្យទៅឲ្យទាន់ពួកដែលនៅពីមុខ ។

សុជាៈ	ដល់ពេលពូទៅធ្វើពេទ្យចិន តើពីណាគេដែលមករើសពូឲ្យទៅធ្វើពេទ្យចិន?

ជនៈ	អត់ស្គាល់គេផង ។

សុជាៈ	តែមានគេមករើស?

ជនៈ	បាទ! ។

សុជាៈ ហើយមានអ្នកដែលទៅធ្វើពេទ្យនៅកន្លែងផ្សេងៗទៀតទេ?

ជនៈ មិនដឹងទេ ។

សុជាៈ ចុះក្រៅពីអ្នកដែលទៅធ្វើពេទ្យ ទៅកន្លែងណាខ្លះទៀតទៅ?

ជនៈ ទៅតម្បាក្រមារអីឯណាណោះ ។

សុជាៈ ទៅធ្វើពេទ្យប៉ុន្មាននាក់ទៅ?

ជនៈ តែពីរអ្នកទេ ។

សុជាៈ ឈ្មោះអីដែរ?

ជនៈ អាហួរ ។

សុជាៈ ផ្ទះនៅឯណាដែរ?

ជនៈ ផ្ទះនៅកំពង់លែងណាណោះ ។

សុជាៈ គិច អ៊ីង ប៊ុនហួរ សព្វថ្ងៃដឹង ។

ជនៈ អត់ទេ អានេះកាលនោះងាប់បាត់ហើយ ។

សុជាៈ នៅមានឈ្មោះ អ៊ីង ប៊ុនហួរ មួយនៅរស់ដែរណា សព្វថ្ងៃគាត់ជាខកញ្ញាណា ហើយគាត់មានអាយុប្រហែលជាពូដែរ គាត់មានស្រុកកំណើតនៅកំពង់លែងដែរ ។

ជនៈ អត់ទេអានេះងាប់ហើយ រាងខ្មៅហើយល្អិត ។

សុជាៈ អ៊ីង ប៊ុនហួរ ហ្នឹងគាត់មានរាងដូចជាពូដែរ ស្គមហើយខ្មៅចឹងដែរ ទៅកំពង់លែងសាលាស្រុកវត្តអារាមអីគាត់ធ្វើឲ្យគេច្រើនដែរ អត់នេះក្រែងលពូបែកគ្នាយូរអី!

ជនៈ អត់ទេអានោះងាប់បាត់ហើយ កាលរត់ទៅយួន កាលនោះវាឡើងទៅលិច ហើយកាលនោះពួកអាអស់នោះមកប្រាប់ខ្ញុំនៅកន្លែងដែលខ្ញុំធ្វើការណា វាថាអស់នោះងាប់អស់ហើយ ហើយខ្ញុំសួរថាវាអត់ទៅផ្ទះទេចុះ ហើយអាអស់នោះវាពិការដែរខ្ញុំទៅផ្ទះបណ្តោយទៅ ពីព្រោះនឹកម៉ែដងមិនដែលបានជួបម៉ែដង ។

សុជាៈ ហួរហ្នឹងឈ្មោះអីហួរ?

ជនៈ ភ្លេចដឹតាវាបាត់ហើយដូចជា ញេប ហួរ ។

សុជាៈ គាត់ទៅធ្វើពេទ្យចឹងដែរ?

ជនៈ ទៅធ្វើដែរ ជួបគ្នានៅហ្នឹងហើយស្គាល់គ្នានៅហ្នឹង ។

សុជាៈ	គេឲ្យទៅធ្វើអីគេ មុនដំបូងដែលគេឲ្យទៅធ្វើពេទ្យ?

ជនៈ	គេឲ្យទៅរៀន គេឲ្យរៀនចាក់ខ្នើយចាក់អីទៅ ។

សុជាៈ	រៀនចាក់ខ្នើយ ហើយពេទ្យហ្នឹងជាពេទ្យខាងវះកាត់ ឬក៏ជាពេទ្យកុមារ ពេទ្យខាងជម្ងឺទូទៅ?

ជនៈ	ពេទ្យគេរៀនចាក់ដែរ ។

សុជាៈ	ចុះពីណាគេជាអ្នកបង្រៀន?

ជនៈ	ភ្លេចអស់ហើយ យូរដែរហើយ ។

សុជាៈ	ខ្មែរ?

ជនៈ	ខ្មែរ ។

សុជាៈ	ចុះមានចិនដែលទេ?

ជនៈ	អត់មានទេ ។

សុជាៈ	គេបង្រៀនយើងប៉ុន្មានទៅ បានគេឲ្យយើងទៅអនុវត្តន៍ចាក់អ្នកជម្ងឺអី?

ជនៈ	គេបង្រៀនយើង២-៣ខែអីណោះ ហើយគេអោយនៅរៀនផង ដើរឲ្យថ្នាំគេផងរៀនចាក់ផងទៅណា ដល់យើងចេះចាក់ទៅបានគេឲ្យចាក់ទៅ ដើរតាមតែអាធំៗទៅពីព្រោះអាធំៗគេជាអ្នកដឹកនាំ តែអាធំៗគេឲ្យចាក់គឺចាក់តាមគេទៅ ថ្នាំនៅសម័យនោះស្រួលដែរ ។

សុជាៈ	ចុះគេមានសរសេរអក្សរខ្មែរនៅលើថ្នាំហ្នឹង?

ជនៈ	បាទ! ។

សុជាៈ	ហើយហូវហ្នឹងគេអាយុបងពូឬប្អូនពូ?

ជនៈ	អត់ទេដំណាលគ្នា ។

សុជាៈ	ហើយហូវហ្នឹងគាត់ធ្វើខាងពេទ្យអីដែរ?

ជនៈ	នៅពេទ្យជាមួយគ្នា ផ្នែកជាមួយគ្នា ដេកនៅជាមួយគ្នា បានតែពីរអ្នកហ្នឹងឯង ហើយនឹកឃើញទៅដល់នោះបានខេត្តកំពង់ឆ្នាំងពីរអ្នកវិញហើយ ។

សុជាៈ	ដល់ពេលដែលពូទៅធ្វើពេទ្យអីចឹង តើគេអត់មានឲ្យទៅធ្វើការងារអីផ្សេងទៀតទេ ឬក៏ធ្វើតែពេទ្យមួយទេ?

ជនៈ	បាទទេ! ។

សុជាៈ	គេមានឲ្យទៅទទួលភ្ញៀវ ទៅមើលសិល្បៈអីដែលទេ?

ជនៈ	កាលនោះបានទៅមើលម្តងដែរ ។

សុជាៈ	ទៅមើលនៅឯណាដែរ?

ជនៈ	ទៅមើលនៅស្តាត ។

សុជាៈ	គេដឹកយកទៅឲ្យមើល?

ជនៈ	ដល់ពេលគេឲ្យទៅបានគេទៅដឹក ។

សុជាៈ	ទៅមើលសិល្បៈហ្នឹង មើលរឿងអីខ្លះទៅ?

ជនៈ	រឿងអីខ្ញុំអត់សូវចាំទេ អត់សូវស្គាល់ទេ ។

សុជាៈ	ចុះទៅទទួលភ្ញៀវអីនៅពោចិនតុង នៅវាំងអីនោះ?

ជនៈ	ខ្ញុំអត់ដែលទៅទេ អាធំៗបានគេឲ្យទៅពួកខ្ញុំអាតូចៗអត់ដែលទៅទេ ។

សុជាៈ	ពូនៅមុំណា?

ជនៈ	នៅជិតកន្លែងពេទ្យ១-៧៩ យើងឥឡូវនេះ ។

សុជាៈ	នៅជិតវត្តភ្នំ នៅទល់មុខពេទ្យ១-៧៩ហ្នឹង?

ជនៈ	បាទ! នៅប្រឆិតហ្នឹង ។

សុជាៈ	គេមើលអីដែរ?

ជនៈ	មើលទាហានជង ដូចថាមានទាហានដែលមានរបួសមកពីព្រំដែនអី ។

សុជាៈ	អ្នករបួសដែលទៅវៃវៀតណាមហ្នឹង?

ជនៈ	បាទ! ។

សុជាៈ	មានច្រើនគ្នាដែលទេ?

ជនៈ	ច្រើនគ្នាដែរ តែមិនដឹងជាពីណាពីណីអីទេ មកច្រើនដែររាប់រយដែរហ្នឹង ។

សុជាៈ	ពេលអ្នកជង្ស៊ីមកពីខាងព្រៃវែង ស្វាយរៀង ពូមានដែលសួរគេថាគាត់ត្រូវរបួសដោយសារតែមូលហេតុអីដែលទេ?

ជនៈ	មានអាខ្លះគេសែងមកអី គេដាក់ឡានដាក់អីមក ហើយខ្ញុំអត់ដែលទៅយកទេគឺនៅតែកន្លែងដើរឲ្យថ្នាំអីគេទេ ហើយហ្នឹងនៅរៀនចាក់រៀនអី ។

សុជាៈ	ដល់ពេលដែលពូទៅធ្វើការអីនៅហ្នឹងទេ តើមានដែលទទួលដំណឹងអីពីខាងអ្នកផ្ទះទៅដែលទេ?

ជនៈ	អត់ទេអ្នកនៅខាងនេះក៏អត់ ហើយអ្នកនៅខាងនោះក៏អត់ដែរ ។

សុជាៈ ចុះមានដែលសុំគេមកលេងផ្ទះដែលទេ?

ជនៈ អត់ដែលផង ពីព្រោះមិនដឹងទៅធ្វើច្បាប់នៅឯណាឯណីអីទេ ។

សុជាៈ មានដែលឃើញអ្នកធំអ្នកអីគេដើរទៅមើលនៅកន្លែងពូធ្វើការអីដែលទេ?

ជនៈ មានដែល ។

សុជាៈ ហើយមានស្គាល់គេដែលទេ?

ជនៈ អត់ស្គាល់ទេ បើមិនដឹងជាគេមកពីណាអីណីទេ បើឃើញតែខោរអាវគគោកគដីហ្នឹងដូចៗគ្នា មិនដឹងជាអ្នកណាធំអ្នកណាតូចអី ។

សុជាៈ មានស្គាល់ប្រធានពេទ្យហ្នឹងដែលទេ ឈ្មោះអីដែរ?

ជនៈ យូរដែរហើយ ហើយកាលនោះខ្ញុំមិនសូវជាបានយកចិត្តទុកដាក់ផង ។

សុជាៈ ហើយការងារធ្វើពេទ្យហ្នឹង នៅពេលដែលយើងធ្វើខុសដូចថាឲ្យថ្នាំទៅអ្នកជម្ងឺអីខុសចឹងម៉េចដែរ?

ជនៈ អត់ទេ គឺមានគេប្រាប់គេថាឲ្យអានេះទៅ ហើយចេះតែដើរទៅតាមគេទៅ អាធំគេប្រាប់អាតូចគេថាហែ្អឲ្យថ្នាំនេះទៅ ។

សុជាៈ ពូមានដែលធ្វើខុសអីដែលទេ ដូចថាយើងធ្វើការតែងតែមានខុសអីបន្តិចបន្តួចហើយ ដូចថាឲ្យថ្នាំច្រឡំអី?

ជនៈ អត់ច្រឡំផងថ្នាំហ្នឹង ថ្នាំប៉ុប៉ិនណាណីហើយសុទ្ធតែដូចជាគ្រាប់ប្រែបែក ថ្នាំវាសូន្យហើយបិទផ្លាកប៉ុប៉ិនណាណី ។

សុជាៈ ថ្នាំបារាំងឬក៏ថ្នាំខ្មែរយើង?

ជនៈ ថ្នាំខ្មែរ ។

សុជាៈ ថ្នាំស្ងួរ?

ជនៈ មិនដឹងជាគេស្ងួរនៅឯណាផង ។

សុជាៈ មិនមែនអាប្រភេទថ្នាំបារាំងដូចយើងឥឡូវទេ?

ជនៈ ទេ! មិនមែនទេ តែមានអាថ្នាំវិតាមីនសេគេជូរអែមៗ ខ្ញុំស៊ីដែរហ្នឹងណាស៊ីទាំងដៃៗដែរហ្នឹង ។

សុជាៈ ចុះចំណែកការហូបចុកវិញ?

ជនៈ ហូបចុកយ៉ាប់ណាស់ ។

សុជាៈ មួយពេលគេឲ្យយើងប៉ុន្មានពេល?

ជនៈ មិនទៀតផង ដូចថានៅថ្ងៃណាដែលថាមានបុណ្យគេទៅពីរពេលទៅ ។

សុជាៈ ចុះមានបន្ថែមអីដែលទេ?

ជនៈ ជួនកាលមាន ជួនកាលអត់ដែរ ។

សុជាៈ ចុះពូមានដែលទៅអ្នកជម្ងឺអីដែលទេ?

ជនៈ ខ្ញុំអត់ដែលទេ ពីព្រោះខ្ញុំតូចៗគេអត់ឲ្យទៅណាទេ ដែលតែគេអ្នកធំៗទេ ពួកខ្ញុំអាតូចៗអត់ដែលមានទៅណាទេ បើទៅណាបើអត់មានស្គាល់ផង ។

សុជាៈ ទៅនេះតើគេមានដែលធ្វើប្រវត្តិរូបយើងដែលទេ?

ជនៈ ទេ! កាលទៅនោះគេចំរាញ់ណាស់ដែរ តែកាលពីដើមខ្ញុំអត់មានកាំភ្លើងដែរ ។

សុជាៈ គេចំរាញ់សួរពូដែរ តើគេសួររកម៉េចដែរ?

ជនៈ គេសួរថាមានធ្លាប់ធ្វើជាទាហានដែលអត់ មានធ្វើអីអត់ រួចសួរឯណាផ្ទះក្បឿងផ្ទះអី ។

សុជាៈ ចុះពូប្រាប់គេថាម៉េច?

ជនៈ ខ្ញុំប្រាប់គេថាមានផ្ទះក្បឿងមួយខ្នងដែរ ។

សុជាៈ ចុះឪពុកពូធ្វើអីដែរ?

ជនៈ ឪពុកខ្ញុំអត់មានធ្វើអីទេ គឺគាត់នៅតែហ្នឹងដែរ ។

សុជាៈ គេសួរញឹកញាប់ដែលទេ?

ជនៈ ញឹកណាស់ដែរ ។

សុជាៈ អញ្ចឹងបានន័យថានៅក្នុងពេទ្យហ្នឹង មានអ្នកដែលគេយកទៅសម្លាប់ទៅអី?

ជនៈ នៅក្នុងហ្នឹងមាន តែគេថាយកទៅនេះទៅព្រំដែនអី ទៅនៅអគ្គភាពចេះចុះអាហ្នឹងមានចឹងដែរខ្លះអាធំៗគេថាលែងឲ្យនៅនេះហើយ បញ្ជូនវាឲ្យទៅនៅអគ្គភាពនោះ ។

សុជាៈ ហើយក្រោយមកមានដែលឃើញត្រឡប់មកវិញដែលទេ?

ជនៈ អត់ដែលឃើញផង បាត់អស់ ហើយកាលនោះខ្ញុំអត់សូវដែលបានដើរផង ។

សុជាៈ តែពូសន្និដ្ឋានថា តើគេយកទៅដាក់នៅសហករណ៍មែនឬក៏គេយកទៅសម្លាប់?

ជនៈ ដឹងដឹងជាគេយកទៅដាក់នៅសហករណ៍ ឬក៏យកទៅធ្វើពេទ្យ ធ្វើទាហាននៅឯណាទេ ឬក៏គេសម្លាប់ចោលបណ្តោយក៏មិនដឹង ។

សុជាៈ កាលនៅជំនាន់នោះ តើពូមានដែលដឹងថាមានការសម្លាប់មនុស្សឬក៏ធ្វើទារុណកម្មមនុស្សដែលទេ តើពូមានដែលដឹងឬឃើញដែលទេ?

ជនៈ នៅក្រោយលឺតែថាសម្លាប់ បើកាលនៅមុខអត់មានទេ។

សុជាៈ នៅឯណា?

ជនៈ នៅសហករណ៍ក្រោយ នៅសហករណ៍ដែលខ្ញុំរត់មកហ្នឹងគេថាសម្លាប់អស់រលីងហើយ កាលដែលនៅឆ្នាំ៧៥ នៅនោះគឺអត់មានប្រជាជនមែន គឺអត់មានប្រជាជនទេ។

សុជាៈ តែពូដឹងថាការសម្លាប់ហ្នឹងនៅក្រោយ៧៩ហើយទេ?

ជនៈ សម្លាប់នៅមុន៧៩ កាលដែលខ្ញុំរត់មកហ្នឹងគឺនៅក្រោយឆ្នាំ៧៩ទេ។

សុជាៈ អញ្ចឹងពូដឹងគឺដឹងនៅពេលដែលពូរត់មកទេ?

ជនៈ ដឹងនៅពេលដែលរត់មកទេ រត់មកហ្នឹងខ្ញុំស្មានតែយួនបាញ់គេ ឃើញខ្មោចងាប់គគោកគគីដល់តែសួរម៉ែទៅ គាត់ប្រាប់ថាសុទ្ធតែជាពួកបុព៌ទេ ខ្ញុំស្មានតែយួនសម្លាប់តាមពិតអត់ផង។

សុជាៈ ពួកបុព៌?

ជនៈ ពួកបុព៌ កាលនោះគេថានៅធ្វើព្រលាននៅនេះនោះ។

សុជាៈ ហើយគេយកមកសម្លាប់នៅហ្នឹង?

ជនៈ គេយកមកសម្លាប់នៅលិចណោះ តែមិនដឹងជានៅឯណាផងកាលដែលពួកខ្ញុំរត់ហ្នឹង ហើយខ្ញុំអត់ដែលនៅហ្នឹងផង បានជាខ្ញុំអត់ស្គាល់។

សុជាៈ ឃើញច្រើនទេ?

ជនៈ ឃើញខ្មោចងាប់ច្រើនណាស់ នៅគរគ្នាពេញតែព្រៃ។

សុជាៈ ចុះឥឡូវគេគាស់អស់ឬនៅ?

ជនៈ គេគាស់អស់ហើយ គេគាស់តាំងពីឆ្នាំ៧៩ គឺមានគេអ្នកដើរគាស់។

សុជាៈ ហើយទាំងអស់ហ្នឹង សុទ្ធតែជាទាហាន ឬក៏ជាប្រជាជន?

ជនៈ កាលនោះម៉ែខ្ញុំគាត់ប្រាប់ថាពួកបុព៌។

សុជាៈ តែពួកបុព៌ហ្នឹង វាមានទាហានហើយហ្នឹងប្រជាជន?

ជនៈ ដឹងអី តែគេថាទាហានដែលមកធ្វើព្រលាន ហើយខ្ញុំអត់មានបាននៅហ្នឹងផង បានជាខ្ញុំអត់មានដឹង

សុជាៈ ពេលដែលរត់មកនៅឆ្នាំ៧៩ហ្នឹង ឬក៏នៅក្នុងភ្នំពេញមានដែលឃើញគេចាប់មនុស្ស ឬក៏ចង មនុស្សអីដែលទេ?

ជនៈ អត់ដែលមានផង គឺគេជូនយកមកហ្មង ។

សុជាៈ អត់ទេ កាលដែលនៅពេទ្យព-១នោះ នៅក្នុងពេទ្យពូណា តើពូមានដែលឃើញគេចាប់មនុស្ស អីដែលទេ?

ជនៈ កាលនៅជំនាន់មុន ខ្ញុំអត់ដែលបានឃើញទេ គ្រាន់តែឃើញគេដូរដោះទៅដាក់នៅកន្លែងនេះ កន្លែងនោះ ទៅអង្គភាពនេះអង្គភាពនោះ ។

សុជាៈ តែពេលដែលគេមកហៅដកហ្នឹង តើមានឡានគេមកយកទៅឬក៏ទៅដោយខ្លួនឯង?

ជនៈ អត់ទេមានមេគេហៅទៅ ។

សុជាៈ នៅកាលជំនាន់នោះ ពូមានដែលលឺគេនិយាយពីរឿងគិញសេអ៊ីអាអីដែលទេ?

ជនៈ អត់ដែលលឺទេ ។

សុជាៈ មានស្គាល់មេដឹកនាំខ្មែរក្រហមធំៗដែលទេ មានដែលលឺឈ្មោះដែលទេ?

ជនៈ ដែលលឺគេផ្សាយវ៉ាដ្យូ ។

សុជាៈ លឺថាម៉េចខ្លះ?

ជនៈ លឺគេថា ប៉ុល ពត ។

សុជាៈ ហើយមានពីណាទៀត?

ជនៈ លឺតែគេថា ប៉ុល ពត ហើយហ្នឹង អៀង សារី ។

សុជាៈ ផ្សាយញឹកញាប់ដែលទេ តាមវ៉ាដ្យូអីហ្នឹង?

ជនៈ វ៉ាដ្យូគេផ្សាយញឹកញាប់ដែល ។

សុជាៈ គេថា អៀង សារី ធ្វើអីហើយ ប៉ុល ពត គេធ្វើអីដែរ?

ជនៈ ប៉ាទ! ។

សុជាៈ ហើយ អៀង សារី គេធ្វើអីដែរ?

ជនៈ មិនដឹងជាធ្វើអីទេ តែគេស្តេចដែរ ។

សុជាៈ ហើយពូមានដែលជួបមុខ អៀង សារី ដែលទេ?

ជនៈ អត់ដែលទេ ។

សុជាៈ ចុះដល់ពេលដែលវៀតណាមចូលមក?

ជនៈ ដល់ពេលវៀតណាមចូលមក ខ្ញុំរត់ចេញមផ្ទះ ។

សុជាៈ ជិះអីមកទៅ?

ជនៈ រត់ដើរហូត ។

សុជាៈ ដើរតាមផ្លូវឬក៏ម៉េច?

ជនៈ ដើរមកតាមផ្លូវ ។

សុជាៈ ចុះគេអត់មានគៀងគរអីអោយទៅណាទេ?

ជនៈ អត់ទេ គ្រាន់តែគេចូលរត់បែកគ្នាអស់ ។

សុជាៈ ហើយកាលហ្នឹងមកគ្នាច្រើនដែលទេ?

ជនៈ មកកាលហ្នឹងមកគ្នាច្រើន មកតាមនេះ ។

សុជាៈ ចុះមេពួអី ប្រធានពួអី គេអត់មានប្រាប់ថាឲ្យរត់ទៅណាជុំគ្នាអីទេ?

ជនៈ អត់ទេ គេរត់ចោលអស់ហ្នឹងពួកអាធំៗ គឺនៅតែអាតូចៗទេ ដល់នៅតែអាតូចរត់ដែរហ្នឹង ។

សុជាៈ ចុះអ្នកជម្ងឺ?

ជនៈ អ្នកជម្ងឺនៅហ្នង់ខ្លះ រត់ខ្លះដែលហ្នឹង ។

សុជាៈ ពូរត់មកដល់ផ្ទះប៉ុន្មានថ្ងៃ?

ជនៈ ខ្ញុំមកដល់ហ្នឹងប្រហែលជា៧ថ្ងៃ ។

សុជាៈ ពូរត់មកគឺសំដៅចូលមកហ្នឹងហ្នង?

ជនៈ ខ្ញុំរត់មកដល់វត្តេង ហើយមកដល់ជួបម៉ែខ្ញុំហ្នឹងបណ្តោយ ។

សុជាៈ បានជួបម្តាយហ្នង?

ជនៈ មកដល់ជួបម្តាយ ។

សុជាៈ ហើយអត់មានទៅណាទៀតទេ?

ជនៈ អត់មានទៅណាទេ ហើយគេមកហៅចាប់ឲ្យទៅធ្វើឈ្លប ខ្ញុំថាអត់ធ្វើទេព្រោះឃើញម៉ែយូរហើយ ខ្ញុំអត់ធ្វើទេ ។

សុជាៈ គេឲ្យនៅធ្វើឈ្លបនៅភូមិហ្នឹង?

ជនៈ បាទ! ។

សុជាៈ ហើយខាងណាគេឲ្យធ្វើ?

ជនៈ នៅហ្នឹងខាងពតហ្នឹង ហើយខ្ញុំថាអត់ទៅធ្វើទេព្រោះខ្ញុំបាត់ម៉ែខ្ញុំយូរហើយ ខ្ញុំអត់ទៅទៀតទេ ។

សុជាៈ ពូបានឆ្លងកាត់របបខ្មែរក្រហមហ្នឹងមក តើពូគិតថារបបហ្នឹងយ៉ាងម៉េចដែរ?

ជនៈ របបហ្នឹងយ៉ាប់ណាស់ បែកបាក់ម៉ែឪអស់ ព្រោះមិនដែលបានឃើញមុខគ្នាផង ។

សុជាៈ ចុះតើរបបហ្នឹងមានកន្លែងណាដែលថាល្អត្រឹមត្រូវដែលទេអ៊ី?

ជនៈ ខ្ញុំថាដូចអត់មានកន្លែងណាដែលថាល្អផង គ្រាន់តែខ្ញុំរត់មកដល់ផ្ទះលឺតែថាអត់មានអីស៊ី ហើយទៅស្លាប់នៅឯណាកគោកគដី ។

សុជាៈ ហើយកាលដែលនៅភ្នំពេញពូអត់មានដឹងទេ?

ជនៈ អត់មានដឹងទេ ។

សុជាៈ ចុះកាលមុនពូទៅ អាពេលដែលគេជម្លៀសប្រជាជនមក តើគេចាប់ផ្តើមសម្លាប់ឬនៅ?

ជនៈ គេជម្លៀសមកអស់ហើយ ប៉ុនតែនៅមានមនុស្សនៅតាមហ្នឹងនៅឡើយ ។

សុជាៈ ចុះពេលដែលពូមកវិញ?

ជនៈ សូម្បីតែអ៊ំខ្ញុំក៏គេសម្លាប់ចោលដែរ គាត់ធ្វើជាទាហាន?

សុជាៈ គាត់ធ្វើជាទាហាន លន់ ណុល?

ជនៈ បាទ! ។

សុជាៈ គាត់ជម្លៀសពីភ្នំពេញមក ពីកំពង់ឆ្នាំងមក?

ជនៈ បាទ! ។

សុជាៈ ចុះកូនចៅគាត់?

ជនៈ នៅរាល់ថ្ងៃ ។

សុជាៈ អញ្ចឹងស្លាប់តែគាត់មួយទេ?

ជនៈ បាទ! កូនគាត់បងគេនៅរាល់ថ្ងៃ ។

សុជាៈ ចុះប្រពន្ធគាត់?

ជនៈ ស្លាប់ដែរហើយ ។

សុជាៈ គេសម្លាប់ដែរ?

ជនៈ អត់ទេ គាត់ទើបឈឺស្លាប់នៅជំនាន់នេះទេ ។

សុជាៈ	តាំងពី៧៩មក តើមានដែលគេមកសួរនាំពូចឹងដែលទេ?

ជនៈ	អត់ដែលទេ ។

សុជាៈ	ចុះពេលដែលមានពួកខ្ញុំមកសួរចឹង តើពូមានអារម្មណ៍ម៉េចដែរ ភ័យដែលទេ?

ជនៈ	អត់មានអារម្មណ៍ភ័យអីទេ ។

សុជាៈ	ហើយពូគិតថាម៉េចដែរ ពេលដែលមានពួកខ្ញុំមកសម្ភាសន៍ចឹង?

ជនៈ	មកហ្នឹងខ្ញុំគិតថា បែបមានដំណឹងប្អូនខ្ញុំអីនៅឯណាដែលទេ អត់ស្លាប់អីមានដឹងអី ។

សុជាៈ	ប្អូនពូឈ្មោះអីខ្លះ?

ជនៈ	ង៉ុយ ។

សុជាៈ	ចុះមួយទៀត?

ជនៈ	ឌុន តែគេថាស្លាប់អស់ហើយ តែក្រែងតែគេថាស្លាប់ៗ តែក្រែងលវាកប់នៅឯណាអី ។

សុជាៈ	ចុះពូជន?

ជនៈ	បាទ! ក្រែងលវាទៅនៅស្រុកគេស្រុកអី អាខ្លះគេទៅនៅឯណាអី ទៅនៅចិនអី ។

សុជាៈ	ឌុនហ្នឹង គាត់មានទៅធ្វើទ័ពធ្វើអីចឹងដែរ គាត់ជាបងពូឬក៏ជាប្អូនពូ?

ជនៈ	បង ។

សុជាៈ	ពូមានដែលនិយាយរឿងរ៉ាវដែលពូនិយាយប្រាប់ខ្ញុំមកហ្នឹងហែរចឹង តើពូមានដែលនិយាយប្រាប់កូនពូដែលទេ?

ជនៈ	អត់ដែលនិយាយ ។

សុជាៈ	ថីបានអត់ដែលនិយាយ?

ជនៈ	បើនិយាយគឺនិយាយពីរឿង កាលដែលនៅជំនាន់ពតអត់បាយអត់ទឹកអី ។

សុជាៈ	ពូខស្សាប់និយាយដែរ?

ជនៈ	បាទ! ។

សុជាៈ	ហេតុអីបានជាពូនិយាយប្រាប់ក្មេងៗចឹង?

ជនៈ	ឲ្យវាដឹងថាកាលនៅជំនាន់នោះពិបាកណាស់ ហើយបើសិនណាជាកូនចៅវាពិបាកប្រហែលខ្ញុំ ពួកវាខំប្រហែលខ្ញុំវិន បើស្រូវញុំវមិនដឹងជាយកទៅណាទេ ។

សុជាៈ	អញ្ចឹងកាលនោះប្រឹងទាំងអស់គ្នាហ្មង?

ជនៈ ច្រើនហ្នឹង ។

សុជាៈ តែមិនច្រើនមិនរស់ទេ?

ជនៈ បើមិនច្រើនទេ គឺងាប់ខ្ទេចអស់ហើយ ។

សុជាៈ ចុះរាល់ថ្ងៃនេះបើសិនជាពូដឹងអ្នកដែលធ្វើបាបពូឬក៏សម្លាប់បងពូអី ហើយគេនៅរស់នៅជិតខាងពូអី តើពូមានអារម្មណ៍ចង់សងសឹកគេដែលទេ?

ជនៈ គេស្លាប់អស់បាត់ហើយ ។

សុជាៈ តែបើសិនជាគេនៅរស់រហូតមកដល់សព្វថ្ងៃនេះ?

ជនៈ ទេ! ខ្ញុំអត់មានហ៊ានធ្វើអីគេទេ ហើយគេក៏មានកូនគេដែរ ។

សុជាៈ ចុះកូនចៅគាត់ហ្នឹង តើពូគិតថាប្រាប់កូនចៅពូមិនអោយទៅលេងជាមួយឬមិនរាប់អានជាមួយកូនចៅអ្នកហ្នឹងដែលទេ?

ជនៈ អ្នកណា!

សុជាៈ អ្នកដែលធ្វើបាបគ្រួសារពូអីចឹង?

ជនៈ អត់ដែលទេខ្ញុំ អត់ដែលប្រាប់ទេ ពីព្រោះខ្ញុំអត់ដែលនៅហ្នឹងផង អត់មានដឹងថាអ្នកណាកាចអីស្លូតអីផង ។

សុជាៈ ចុះបើសិនជាពូដឹង?

ជនៈ អត់មានដឹងផង បើជាដឹងវិញក៏វាអន់ចិត្តដែរ តែខ្ញុំវាអត់ដែលដឹង ។

សុជាៈ តែអត់មានអារម្មណ៍ចង់សងសឹកគេទេ?

ជនៈ អត់ផង ។

សុជាៈ ពូរាល់ថ្ងៃមានដែលលឺរឿងតុលាការដែលគេបង្កើតឡើងដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហម តើពូមានដែលលឺដែលទេ?

ជនៈ លឺគេផ្សាយតាមវិទ្យុរាល់ថ្ងៃ ។

សុជាៈ លឺគេផ្សាយតាមវិទ្យុ?

ជនៈ លឺពីរឿងតុលាការ ។

សុជាៈ ហើយពូមានអារម្មណ៍យ៉ាងម៉េចដែរ ពេលដែលលឺអញ្ចឹង?

ជនៈ ទេ! បុណ្យឲ្យតែគាត់អាមេៗហ្នឹង បើថាអាតូចតាចអីគ្នាគ្មានទៅដឹងអីទេ ឲ្យតែគាត់អាមេៗដឹកនាំធំៗ ពួកអាតូចតាចគ្មានដឹងអីទេ ខ្ញុំថាអញ្ចឹង ។

សុជាៈ ហើយតុលាការហ្នឹងគេមិនបង្កើតឡើងដើម្បីកាត់ទោសមេដឹកនាំធំៗ ?

ជនៈ បាទ! ។

សុជាៈ ពូលឺចឹងដែរ ចុះពូគិតថាមេដឹកនាំតូចតាចគួរតែធ្វើម៉េច?

ជនៈ អាតូចតាចខ្ញុំយល់ថានៅពេលដែលគេយកអាធំអស់ ពួកអាយតូចតាចអត់មានអីទៀតទេ វាអត់មានដឹកនាំអីទៀតទេ ព្រោះអស់អាធំហើយ ។

សុជាៈ ចុះហេតុអីបានជាយកតែអ្នកធំៗទៅកាត់ទោស?

ជនៈ អាអ្នកធំជាអ្នកនាំខុស កាលហ្នឹងវាគំរាមកំហែងដល់ចឹងភ័យខ្លាច ដូចរាល់ថ្ងៃបើអ្នកធំមកគំរាមកំហែងចឹងទៅ ប៉ុនអ្នកធំអត់ធ្វើចឹងផង ។

សុជាៈ ពូយល់ថាតុលាការហ្នឹងមានប្រយោជន៍អីដែរ?

ជនៈ ប្រយោជន៍ផ្តល់យុត្តិធម៌ ត្រឹមត្រូវ ។

សុជាៈ ពូគិតថាចង់ឲ្យគេដាក់ទោសអ្នកដែលត្រូវជាប់គុកហ្នឹងកំរិតណាឲ្យស្ងប់ចិត្ត?

ជនៈ អារឿងថាហ្នឹង ខ្ញុំថាក៏បាន អ្នកធំថាក៏បានៗ បើខ្ញុំថាដាក់១០ឆ្នាំ ២០ឆ្នាំអីទៅ ប៉ុនអ្នកធំគេត្រូវគ្នាគេ គេលែងបាត់ទៅម៉េច? យើងគ្រាន់តែថា ។

សុជាៈ ឥឡូវយើងថាមើល! យើងតាមអារម្មណ៍ តាមគំនិតរបស់យើងប៉ុន្មាន?

ជនៈ និយាយពីអារម្មណ៍របស់ខ្ញុំវិញ មិនដែលយកចិត្តទុកដាក់អីទេ ។ បើតាមចិត្តរបស់ខ្ញុំវិញដូចថា....

សុជាៈ ឥឡូវនេះ ដូចថាមានអ្នកឈ្លបភូមិឈ្លបឃុំអីហ្នឹងណា ភូមិឃុំស្រុកអីដែលនៅខ្មែរក្រហមហ្នឹងណា ហើយពួកអស់ហ្នឹងគេមិនត្រូវគេយកទៅកាត់ទោសទេ បើតាមគំនិតគេណាដូចជាគំនិតពូដែរ ហើយពួកហ្នឹងក៏ធ្វើខុសដែរ តើពូឲ្យពួកគាត់ធ្វើម៉េចដែរចំពោះប្រជាជនខ្មែរដែលជាអ្នករងគ្រោះ?

ជនៈ តែខ្ញុំថាបែបខ្លាចរត់អស់ហើយ ពីព្រោះប្រជាជនឥឡូវគេមានសិទ្ធដែរ គេមានអំណាចដែរ ។

សុជាៈ អំណាចម៉េច?

ជនៈ អំណាចហ៊ានឈ្លោះហានតដៃដែរ បើសិនជាកាលនោះអ្នកឯងកាចក៏អត់មានហ៊ាននៅដែរ គឺនៅមិនបានទេបើមិនគេរុកគេឆ្កៀល ។

សុជាៈ តែបើថានៅបានគឺនៅតែស្លូតទេ?

ជនៈ បាទ! ។

សុជាៈ ពូមានដែលលឺរឿងដែលគេកាត់ទោសមេដឹកនាំខ្មែរក្រហម កាលនៅឆ្នាំ៨០ មានលឺដែលទេ?

ជនៈ អត់ដែលលឺទេ ។

សុជាៈ តើគិតថាការកាត់ទោសហ្នឹង តើវាមានការផ្សះផ្សារជាតិដែលទេ?

ជនៈ ខ្ញុំកាត់ហ្នឹងគឺកាត់ដើម្បីសំរាលទោសឲ្យមានការផ្សះផ្សារ ។

សុជាៈ ផ្សះផ្សារម៉េច?

ជនៈ ផ្សះផ្សាររួមដៃគ្នារវាងខ្មែរ ។

សុជាៈ ហើយឧទាហរណ៍បើសិនជាមេដឹកនាំខ្មែរក្រហមណាម្នាក់ដែលគេកាត់ទោសឲ្យជាប់គុក តើពូមានគិតថាមានមេដឹកនាំណាមួយដែលពូគិតចង់ឲ្យលើកលែងទោសវិញ តើមានដែលទេ?

ជនៈ អត់ដឹងទេ......... ។

សុជាៈ ចុះអ្នកដែលធ្លាប់ធ្វើជាឈ្លបភូមិឈ្លបស្រុកហ្នឹង តើពូគិតថាចង់ឲ្យគេមកសុំខមាទោសចំពោះប្រជាជនដែលបានស្លាប់ទៅដែលទេ បើសិនជាគាត់នៅមានជីវិតរស់នៅណា?

ជនៈ ខ្ញុំថាបែបអត់មាននៅទេ ។

សុជាៈ តែចង់ឲ្យពួកគាត់ហ្នឹងមកសារភាពដែលទេ?

ជនៈ បើខ្ញុំអត់មានស្គាល់ថាអ្នកណាធ្វើអីៗផង អត់មានស្គាល់ផង តែខ្ញុំថាមិនចាំបាច់ចឹងទេបែបខ្លាចដោយខ្លួនឯងទេ ចិត្តខ្ញុំនឹលឃើញចឹង ។

សុជាៈ ចំពោះសាសនាព្រះពុទ្ធវិញ តើមានគុណវិត្តឬក៏គុណសម្បត្តិអីដែលទេ ចំពោះការបង្រួបបង្រួមជាតិនឹងការផ្សះផ្សារជាតិ តើមានគុណសម្បត្តិអីខ្លះទៅ?

ជនៈ ខ្ញុំថាបានណែនាំ បានដាក់គៀនឲ្យល្អមិនឲ្យឆក់មិនឲ្យវៃគ្នាអី ។

សុជាៈ ចុះពូយល់ថាយ៉ាងម៉េចដែរចំពោះពាក្យថាយុត្តិធម៌?

ជនៈ ខ្ញុំថាត្រឹមត្រូវ ។

សុជាៈ អញ្ចឹងខ្ញុំអរគុណពូច្រើន!

ជនៈ បាទ! ។